**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ**

**ក្រុមប្រឹក្សាគោលនយោបាយដីធ្លី**

លេខ.០១៩.....សណាន/កគដ

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២

# សេចក្ដីណែនាំ

## ស្ដីពី

## ការពង្រឹងប្រសិទ្ធភាពនៃប្រតិបត្តិការអនុវត្ត នយោបាយចាស់សកម្មភាពថ្មីរបស់រាជរដ្ឋាភិបាលលើវិស័យដីធ្លី

ដើម្បីជំរុញប្រសិទ្ធភាពនៃការអនុវត្តការងារវាស់វែងដីធ្លីជូនប្រជាពលរដ្ឋតាមបទបញ្ជាលេខ ០១ បប ចុះថ្ងៃ ទី០៧ ខែឧសភា ឆ្នាំ២០១២ របស់រាជរដ្ឋាភិបាល ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី និងជាប្រធានគណៈកម្មការត្រួតពិនិត្យការអនុវត្តន៍នយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី សូមធ្វើការណែនាំអំពីការអនុវត្តបន្ថែមពីលើឯកសារដែលមានជាធរមាន ដល់ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋគ្រប់ខេត្ត និងជាប្រធានគណៈកម្មការរដ្ឋបាល ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី និងក្រុមបច្ចេកទេសវាស់វែងដីធ្លី ដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ ដូចតទៅ៖

១. ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត (ដនសស) ត្រូវផ្ដួចផ្ដើមគំនិតជូនអភិបាលខេត្ត ជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្ត និងជាប្រធានគណៈកម្មការរដ្ឋបាល អំពីផែនការកំណត់ទីតាំងតំបន់ចុះបញ្ជីដីតាមលំដាប់អាទិភាព។

២. ប្រធានក្រុមបច្ចេកទេសវាស់វែងដីធ្លី ត្រូវកត់ត្រាវត្តមានប្រចាំថ្ងៃនៃកម្លាំងប្រតិបត្តិការក្រុមបច្ចេកទេសវាស់វែងដីធ្លី លទ្ធផលការងារសំរេចបាន បញ្ហាប្រឈម និងសំណូមពរ ហើយរាយការណ៍ ជូនប្រធានមន្ទីរ ដនសស ត្រឹមម៉ោង ០៦ ល្ងាច ដើម្បីប្រធានមន្ទីរ ដនសស រាយការណ៍ជូនប្រធានក្រុមការងារភូមិភាគ យ៉ាងយូរត្រឹមម៉ោង ៨ យប់។ ទន្ទឹមនេះ ប្រធានមន្ទីរ ដនសស ត្រូវផ្ទៀងផ្ទាត់របាយការណ៍ប្រចាំ០១ថ្ងៃមុន ដែលអគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រ បានផ្ញើជូនតាមរយៈប្រធានក្រុមការងារភូមិភាគ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃរបាយការណ៍ និងផ្ញើត្រឡប់មកវិញជាមួយរបាយការណ៍ប្រចាំថ្ងៃ។

៣. គ្រប់ក្រុមបច្ចេកទេសវាស់វែងដីធ្លី ត្រូវធ្វើផែនការសកម្មភាពការងារសម្រាប់គ្រប់ភូមិគោលដៅ ដែលត្រូវអនុវត្ត ដោយធ្វើការប៉ាន់ស្មានចំនួនគ្រួសារ (ដែលរស់នៅក្នុងភូមិ និងក្រៅភូមិគោលដៅ) ចំនួនក្បាលដី និងពិនិត្យវាយតម្លៃស្ថានភាពភូមិសាស្ត្រ។

៤. ប្រធានក្រុមបច្ចេកទេសវាស់វែងដីធ្លី ត្រូវជួបប្រជុំជាមួយក្រុមយុវជនស្ម័គ្រចិត្ត រាល់ពេលល្ងាច ដើម្បីពិគ្រោះពីវិធានការអនុវត្តផែនការសម្រាប់ថ្ងៃបន្ទាប់ អំពីការងារត្រូវធ្វើ ចំនួនកម្លាំងអនុវត្ត ទីតាំងអនុវត្ត របៀបអនុវត្ត និងដោះស្រាយបញ្ហាជួបប្រទះកន្លងមក ឬចែករំលែកព័ត៌មានទៅវិញទៅមក។

អាស័យដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខណ្ឌ ចំការមន ក្រុងភ្នំពេញ

៥. ប្រធានក្រុមបច្ចេកទេសវាស់វែងដីធ្លី ត្រូវជួបប្រជុំជាមួយសមាជិកក្រុមរបស់ខ្លួនរៀងរាល់ថ្ងៃ ដើម្បីណែនាំ ឬដោះស្រាយបញ្ហា ឬទទួល សំណូមពរ ដើម្បីរាយការណ៍ជូនថ្នាក់លើដោះស្រាយ។

៦. ប្រធានក្រុមបច្ចេកទេសវាស់វែងដីធ្លី ត្រូវជួបប្រជុំជាមួយប្រធានមន្ទីរ ដនសស ០១ ដង ឬ ០២ ដង ក្នុងមួយខែ ទៅតាមស្ថានភាពជាក់ស្តែង ដើម្បីរាយការណ៍ពីលទ្ធផលការងារ បញ្ហាប្រឈម សំណូមពរ និងទិសដៅអនុវត្តបន្ត។

៧. ប្រធានមន្ទីរ ដនសស ត្រូវជួបប្រជុំជាមួយប្រធានយុវជនស្ម័គ្រចិត្តខេត្ត ០២ សប្តាហ៍ម្តង ដើម្បីផ្លាស់ប្តូរព័ត៌មាន ដោះស្រាយបញ្ហាប្រឈម និងសម្របសម្រួលការងារ។

៨. ប្រធានមន្ទីរ ដនសស ឬតំណាង ត្រូវជួបប្រជុំប្រចាំខែ ជាមួយថ្នាក់កណ្តាល ដើម្បីរាយការណ៍ពីលទ្ធផលការងារ បញ្ហាប្រឈម សំណូមពរ និងទិសដៅអនុវត្តបន្ត។

សេចក្តីណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី**

**អ៊ឹម ឈុនលឹម**

*ចម្លងជូន៖*

- *ក្រសួង/ស្ថាប័នជាសមាជិកក្រុមប្រឹក្សាគោលនយោបាយដីធ្លី*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
  *"ដើម្បីជូនជ្រាប"*
- *គ្រប់រាជធានី ខេត្ត*
- *គ្រប់អគ្គនាយកដ្ឋាន និងអង្គភាពជុំវិញក្រសួង ដ.ន.ស.*
- *គ្រប់មន្ទីរ ដនសស រាជធានី ខេត្ត*
  *"ដើម្បីជ្រាប និងអនុវត្ត"*
- *ឯកសារ កាលប្បវត្តិ*